**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**
**លេខ :** ៦០ អនក្រ.បក

# អនុក្រឹត្យ
# ស្តីពី
# លក្ខខណ្ឌនិងនីតិវិធីអំពីការរួមបញ្ចូលគ្នានៃធុរកិច្ច

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៨/៩២៥ ចុះថ្ងៃទី៦ ខែកញ្ញា ឆ្នាំ២០១៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៣២០/៤២១ ចុះថ្ងៃទី៣០ ខែមីនា ឆ្នាំ២០២០ ស្តីពីការតែងតាំង និងកែសម្រួលសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៦ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងពាណិជ្ជកម្ម
- បានឃើញព្រះរាជក្រមលេខ នស/រកម/១០២១/០១៣ ចុះថ្ងៃទី៥ ខែតុលា ឆ្នាំ២០២១ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការប្រកួតប្រជែង
- បានឃើញអនុក្រឹត្យលេខ៣៨ អនក្រ.បក ចុះថ្ងៃទី១៦ ខែមីនា ឆ្នាំ២០២០ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅរបស់ក្រសួងពាណិជ្ជកម្ម
- បានឃើញអនុក្រឹត្យលេខ៣៧ អនក្រ.បក ចុះថ្ងៃទី១៧ ខែកុម្ភៈ ឆ្នាំ២០២២ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅរបស់គណៈកម្មាធិការប្រកួតប្រជែងកម្ពុជា
- យោងតាមសំណើរបស់រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម

## សម្រេច
## ជំពូកទី១
## បទប្បញ្ញត្តិទូទៅ

**មាត្រា១ _ គោលបំណង**

អនុក្រឹត្យនេះកំណត់អំពីលក្ខខណ្ឌនិងនីតិវិធីអំពីការរួមបញ្ចូលគ្នានៃធុរកិច្ច ក្នុងគោលបំណងត្រួតពិនិត្យតាមដាន និងវាយតម្លៃលើផលប៉ះពាល់ចំពោះការប្រកួតប្រជែង។

**មាត្រា២ ._ វិសាលភាព**

អនុក្រឹត្យនេះមានវិសាលភាពអនុវត្តចំពោះរាល់ការរួមបញ្ចូលគ្នានៃធុរកិច្ចដោយផ្ទាល់ឬប្រយោល ដែលមាន ឬអាចមានកម្មវត្ថុ ឬអានុភាពរារាំង រឹតត្បិត ឬបង្ខូចដល់ការប្រកួតប្រជែងគួរឱ្យកត់សម្គាល់នៅក្នុងទីផ្សារនៃព្រះរាជាណាចក្រកម្ពុជា ទោះបីការរួមបញ្ចូលគ្នានៃធុរកិច្ចនោះមានប្រភពនៅក្នុងឬក្រៅប្រទេសក៏ដោយ លើកលែងតែការរួមបញ្ចូលគ្នានៃធុរកិច្ចក្នុងវិស័យជាក់លាក់ដែលមានច្បាប់និងបទប្បញ្ញត្តិជាធរមានរួចហើយ។

**មាត្រា៣ ._ និយមន័យ**

វាក្យសព្ទសំខាន់ៗដែលប្រើក្នុងអនុក្រឹត្យនេះ ត្រូវបានកំណត់និយមន័យដូចខាងក្រោម៖

១_ **ការជូនដំណឹងជាមុន** សំដៅដល់ការជូនដំណឹងជាកាតព្វកិច្ចរបស់ភាគីស្នើសុំរួមបញ្ចូលគ្នានៃធុរកិច្ចមក **គ.ប.ក.** មុនបញ្ចប់ផ្នែកសំខាន់ៗនៃការរួមបញ្ចូលនៃធុរកិច្ច ដូចមានចែងក្នុងជំពូកទី២នៃអនុក្រឹត្យនេះ។

២_ **ការជូនដំណឹងជាក្រោយ** សំដៅដល់ការជូនដំណឹងជាកាតព្វកិច្ចរបស់ភាគីរួមបញ្ចូលគ្នានៃធុរកិច្ចមក **គ.ប.ក.** ក្រោយបញ្ចប់ផ្នែកសំខាន់ៗនៃការរួមបញ្ចូលនៃធុរកិច្ច ដូចមានចែងក្នុងមាត្រា១៣នៃជំពូកទី៣នៃអនុក្រឹត្យនេះ។

៣_ **ការត្រួតពិនិត្យបឋម** សំដៅដល់ការត្រួតពិនិត្យនិងវាយតម្លៃលើការរួមបញ្ចូលគ្នានៃធុរកិច្ចដែលស្នើសុំ ដូចមានចែងក្នុងកថាខណ្ឌទី៣នៃមាត្រា៥នៃអនុក្រឹត្យនេះ។

៤_ **ការត្រួតពិនិត្យបន្ទាប់** សំដៅដល់ការត្រួតពិនិត្យនិងវាយតម្លៃលើការរួមបញ្ចូលគ្នានៃធុរកិច្ចដែលស្នើសុំ ដូចមានចែងក្នុងកថាខណ្ឌទី៥នៃមាត្រា៥នៃអនុក្រឹត្យនេះ។

៥_ **ការរួមបញ្ចូលគ្នានៃធុរកិច្ចខ្សែដេក** សំដៅដល់ការរួមបញ្ចូលគ្នានៃធុរកិច្ចរវាងបុគ្គលដែលធ្វើប្រតិបត្តិការ ឬអាចធ្វើប្រតិបត្តិការនៅក្នុងកម្រិតស្មើគ្នានៃខ្សែច្រវាក់ផលិតកម្មនិងចែកចាយ។

៦_ **ការរួមបញ្ចូលគ្នានៃធុរកិច្ចខ្សែឈរ** សំដៅដល់ការរួមបញ្ចូលគ្នានៃធុរកិច្ចរវាងបុគ្គលដែលធ្វើប្រតិបត្តិការ ឬអាចធ្វើប្រតិបត្តិការនៅក្នុងកម្រិតខុសៗគ្នានៅក្នុងខ្សែច្រវាក់ផលិតកម្មនិងចែកចាយ។

៧_ **ការរួមបញ្ចូលគ្នានៃធុរកិច្ចពហុផលិតផល** សំដៅដល់ការរួមបញ្ចូលគ្នានៃធុរកិច្ចរវាងបុគ្គលដែលមានសកម្មភាពសេដ្ឋកិច្ចផ្សេងៗគ្នានៅក្នុងទីផ្សារមិនប្រកួតប្រជែងគ្នា។

៨_ **ក្រុម** សំដៅដល់អត្តិភាពរវាងបុគ្គលទាំងឡាយដែលស្ថិតនៅក្រោមសិទ្ធិគ្រប់គ្រងរួម ឬរវាងបុគ្គលពីរដែលបុគ្គលមួយមានសិទ្ធិគ្រប់គ្រងលើបុគ្គលមួយទៀត។

៩_ **ភាគីជូនដំណឹង** សំដៅដល់បុគ្គលនីមួយៗដែលបានស្នើសុំរួមបញ្ចូលគ្នានៃធុរកិច្ចឬដែលបានជូនដំណឹងក្រោយបញ្ចប់ការរួមបញ្ចូលគ្នានៃធុរកិច្ច និងអាចរាប់បញ្ចូលទាំងបុគ្គលផ្សេងទៀតដែលជាកម្មវត្ថុនៃការរួមបញ្ចូលគ្នានៃធុរកិច្ចបានធ្វើការជូនដំណឹង។

១០_ **មន្ត្រីស៊ើបអង្កេត** សំដៅដល់មន្ត្រីនៃអគ្គនាយកដ្ឋាន **ក.ប.ប.** ដែលទទួលបានការតែងតាំងជាមន្ត្រីស៊ើបអង្កេតក្រោមច្បាប់ស្តីពីការប្រកួតប្រជែង។

១១_ **ការចេញវិញ្ញាបនបត្រជាមុន** សំដៅដល់ការចេញវិញ្ញាបនបត្រដោយ **គ.ប.ក.** ដូចមានចែងក្នុងមាត្រា១៤នៃអនុក្រឹត្យនេះ។

១២_ **សន្ទស្សន៍អេច-អេច-អាយ(HHI)** សំដៅដល់សន្ទស្សន៍ហឺហ្វិនដល-ហឺហ្សមែន(Herfindahl-Hirschman Index) ដែលត្រូវបានកំណត់ដោយផលបូកនៃការ៉េរបស់ចំណែកទីផ្សារនៃក្រុមនីមួយៗដែលកំពុងប្រកួតប្រជែងក្នុងទីផ្សារពាក់ព័ន្ធ ដើម្បីកំណត់អំណាចប្រមូលផ្តុំទីផ្សារនៃបុគ្គលដែលមានបំណងឬបានរួមបញ្ចូលគ្នា។

១៣_ **សិទ្ធិគ្រប់គ្រង** សំដៅដល់សិទ្ធិក្នុងការគ្រប់គ្រងលើបុគ្គលឬខ្សែធុរកិច្ចរបស់បុគ្គល និងត្រូវបំពេញលក្ខខណ្ឌណាមួយក្នុងចំណោមលក្ខខណ្ឌដូចខាងក្រោម៖

ក_បុគ្គលដែលទទួលបានកម្មសិទ្ធិលើសពី៥០(ហាសិប)ភាគរយនៃភាគហ៊ុន ផលប្រយោជន៍ ឬសិទ្ធិបោះឆ្នោតរបស់បុគ្គលមួយទៀត។

ខ_បុគ្គលដែលទទួលបានកម្មសិទ្ធិឬសិទ្ធិប្រើប្រាស់នៃទ្រព្យសម្បត្តិ ឬខ្សែធុរកិច្ចមួយឬច្រើនរបស់បុគ្គលមួយទៀតលើសពី៥០(ហាសិប)ភាគរយ។

គ_បុគ្គលណាមួយមានសិទ្ធិដូចខាងក្រោម៖

- ធ្វើសេចក្តីសម្រេចដោយផ្ទាល់ឬប្រយោលចំពោះការតែងតាំង ឬការដកចេញនៃសមាជិកភាគច្រើន ឬទាំងអស់នៃក្រុមប្រឹក្សាភិបាល ឬនាយកប្រតិបត្តិជាន់ខ្ពស់នៃបុគ្គលមួយទៀត
- ធ្វើសេចក្តីសម្រេចកែប្រែលើឯកសារបញ្ជាក់សំខាន់ៗរបស់បុគ្គលមួយទៀត
- ធ្វើសេចក្តីសម្រេចលើសកម្មភាពធុរកិច្ចរបស់បុគ្គលមួយទៀត ដែលរួមមានការជ្រើសរើសទម្រង់និងការរៀបចំខ្សែច្រវាក់ប្រតិបត្តិការធុរកិច្ច តំបន់ភូមិសាស្ត្រនៃសកម្មភាពធុរកិច្ច ការបង្កើនការបែងចែក និងការប្រើប្រាស់ដើមទុន ការធ្វើប្រតិបត្តិការជាក់លាក់ជាមួយនឹងអតិថិជនឬអ្នកផ្គត់ផ្គង់ និងការធ្វើសេចក្តីសម្រេចផ្នែកធុរកិច្ចសំខាន់ៗផ្សេងទៀត។

១៤_ **សេចក្តីជូនដំណឹង** សំដៅដល់ការផ្តល់ព័ត៌មានជាលាយលក្ខណ៍អក្សរឬតាមមធ្យោបាយផ្សេងៗដែលធ្វើឡើងដោយ **គ.ប.ក.** ឬអគ្គនាយកដ្ឋាន **ក.ប.ប.** ទៅភាគីជូនដំណឹងនិងភាគីពាក់ព័ន្ធ។

១៥_ **អគ្គនាយកដ្ឋាន ក.ប.ប.** សំដៅដល់អគ្គនាយកដ្ឋានការពារអ្នកប្រើប្រាស់ កិច្ចការប្រកួតប្រជែង និងបង្ក្រាបការក្លែងបន្លំ។

## ជំពូកទី២
## ការជូនដំណឹងមុនពេលបញ្ចប់ការរួមបញ្ចូលគ្នានៃធុរកិច្ច

### មាត្រា៤ _ កាតព្វកិច្ចក្នុងការជូនដំណឹង

ភាគីស្នើសុំរួមបញ្ចូលគ្នានៃធុរកិច្ច ដែលស្ថិតក្នុងលក្ខខណ្ឌណាមួយនៃកម្រិតកំណត់នៃការរួមបញ្ចូលគ្នានៃធុរកិច្ចដែលត្រូវកំណត់ដោយសេចក្តីសម្រេចរបស់ **គ.ប.ក.** មានកាតព្វកិច្ចជូនដំណឹងមក **គ.ប.ក.** មុនពេលបញ្ចប់ការរួមបញ្ចូលគ្នានៃធុរកិច្ច ដោយត្រូវអនុវត្តតាមនីតិវិធី ដូចមានចែងក្នុងជំពូកទី២នៃអនុក្រឹត្យនេះ។

ការរួមបញ្ចូលគ្នានៃធុរកិច្ចទាំងឡាយដែលជាកម្មវត្ថុនៃការជូនដំណឹងជាមុន ដូចមានចែងក្នុងកថាខណ្ឌទី១ខាងលើ មិនត្រូវបានអនុញ្ញាតឱ្យបញ្ចប់ឡើយ លើកលែងតែមានការអនុញ្ញាតដូចមានចែងក្នុងមាត្រា៦នៃអនុក្រឹត្យនេះ។

**គ.ប.ក.** ត្រូវចេញសេចក្តីសម្រេចលើកម្រិតកំណត់នៃការជូនដំណឹងជាមុន អំពីការរួមបញ្ចូលគ្នានៃធុរកិច្ចដោយពិចារណាលើលក្ខខណ្ឌដូចខាងក្រោម៖

ក_ទ្រព្យសរុបនៅក្នុងព្រះរាជាណាចក្រកម្ពុជារបស់ភាគីណាមួយឬក្រុមពាក់ព័ន្ធរបស់ភាគីនោះ ក្នុងឆ្នាំហិរញ្ញវត្ថុមុនឆ្នាំនៃការជូនដំណឹងអំពីការរួមបញ្ចូលគ្នានៃធុរកិច្ចដែលស្នើសុំ។

ខ_ផលរបរសរុបឬចំណូលនៃការបញ្ជាទិញសរុបនៅក្នុងព្រះរាជាណាចក្រកម្ពុជារបស់ភាគីណាមួយ ឬក្រុមពាក់ព័ន្ធរបស់ភាគីនោះ ក្នុងឆ្នាំហិរញ្ញវត្ថុមុនឆ្នាំនៃការជូនដំណឹងអំពីការរួមបញ្ចូលគ្នានៃធុរកិច្ចដែលស្នើសុំ។

គ_តម្លៃប្រតិបត្តិការរបស់ការរួមបញ្ចូលគ្នានៃធុរកិច្ចដែលស្នើសុំនោះ។

**គ.ប.ក.** ត្រូវចេញសេចក្តីសម្រេចដោយឡែកលើកម្រិតកំណត់នៃការជូនដំណឹងជាមុន អំពីការរួមបញ្ចូលគ្នានៃធុរកិច្ចដែលមានភាគីណាមួយជាគ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ ក្រុមហ៊ុនធានារ៉ាប់រង ឬក្រុមហ៊ុនមូលបត្រ ដោយផ្អែកលើលក្ខខណ្ឌដូចមានចែងក្នុងកថាខណ្ឌទី៣ខាងលើ។

**គ.ប.ក.** មានសិទ្ធិធ្វើការកែសម្រួលកម្រិតកំណត់ ស្របតាមស្ថានភាពជាក់ស្តែង។

**គ.ប.ក.** អាចទទួលការជូនដំណឹងអំពីការរួមបញ្ចូលគ្នានៃធុរកិច្ចបាន ទោះបីជាការជូនដំណឹងនោះមិនត្រូវបានធ្វើឡើងពីគ្រប់ភាគីទាំងអស់នៃការរួមបញ្ចូលគ្នានៃធុរកិច្ចក៏ដោយ ប្រសិនបើការជូនដំណឹងនោះមានភ្ជាប់ជាមួយនូវការបង្ហាញហេតុផលជាលាយលក្ខណ៍អក្សរ ដែលធ្វើឱ្យភាគីទាំងអស់មិនអាចបំពេញកាតព្វកិច្ចជូនដំណឹងបានដូចមានចែងក្នុងកថាខណ្ឌទី១ខាងលើ។

**មាត្រា៥ _ ការត្រួតពិនិត្យបឋមនិងបន្ទាប់**

ភាគីស្នើសុំរួមបញ្ចូលគ្នានៃធុរកិច្ច ដែលតម្រូវឱ្យធ្វើការជូនដំណឹងជាមុន ដូចមានចែងក្នុងកថាខណ្ឌទី១នៃមាត្រា៤នៃអនុក្រឹត្យនេះ ត្រូវផ្តល់ឯកសារនិងព័ត៌មានពាក់ព័ន្ធមក **គ.ប.ក.** ដូចមានចែងក្នុងមាត្រា៧នៃអនុក្រឹត្យនេះ។

ក្រោយពីបានទទួលការជូនដំណឹងនៃការរួមបញ្ចូលគ្នានៃធុរកិច្ច **គ.ប.ក.** មានរយៈពេល៧(ប្រាំពីរ)ថ្ងៃនៃថ្ងៃធ្វើការ ដើម្បីចេញសេចក្តីជូនដំណឹងទៅភាគីជូនដំណឹងអំពីការរួមបញ្ចូលគ្នានៃធុរកិច្ច អំពីភាពគ្រប់គ្រាន់ឬមិនគ្រប់គ្រាន់ពាក់ព័ន្ធនឹងឯកសារនិងព័ត៌មានដែលផ្តល់មក **គ.ប.ក.** និងត្រូវអនុវត្តតាមនីតិវិធីដូចខាងក្រោម៖

ក_ប្រសិនបើ **គ.ប.ក.** មិនបានចេញសេចក្តីជូនដំណឹងឆ្លើយតបទៅភាគីជូនដំណឹងក្នុងរយៈពេលដែលបានកំណត់ខាងលើ ការជូនដំណឹងនៃការរួមបញ្ចូលគ្នានៃធុរកិច្ចរបស់ភាគីនោះ ត្រូវចាត់ទុកថាពេញលេញនិងមានសុពលភាព។

ខ_ភាគីជូនដំណឹង ត្រូវផ្តល់នូវឯកសារនិងព័ត៌មានដែល **គ.ប.ក.** តម្រូវបន្ថែម ដើម្បីបំពេញលក្ខខណ្ឌនៃការជូនដំណឹងនៅក្នុងរយៈពេល៣០(សាមសិប)ថ្ងៃនៃថ្ងៃធ្វើការ ក្រោយពីបានទទួលសេចក្តីជូនដំណឹងរបស់ **គ.ប.ក.**។ ប្រសិនបើភាគីជូនដំណឹង មិនបានបំពេញតាមលក្ខខណ្ឌតម្រូវរបស់ **គ.ប.ក.** នោះទេ ការជូនដំណឹងនៃការរួមបញ្ចូលគ្នានៃធុរកិច្ចដែលស្នើសុំនេះត្រូវចាត់ទុកជាមោឃៈ។ ក្នុងករណីនេះ ភាគីស្នើសុំរួមបញ្ចូលគ្នានៃធុរកិច្ច ត្រូវជូនដំណឹងសាជាថ្មីមក **គ.ប.ក.** តាមនីតិវិធីដូចមានចែងក្នុងជំពូកទី២នៃអនុក្រឹត្យនេះ។

បន្ទាប់ពីទទួលបានការជូនដំណឹងពេញលេញ **គ.ប.ក.** មានរយៈពេល៣០(សាមសិប)ថ្ងៃនៃថ្ងៃធ្វើការដើម្បីចេញសេចក្តីជូនដំណឹងទៅភាគីជូនដំណឹង អំពីលទ្ធផលនៃការត្រួតពិនិត្យបឋមលើការរួមបញ្ចូលនៃធុរកិច្ចដែលស្នើសុំ ដោយបញ្ជាក់នូវការសម្រេចណាមួយដូចខាងក្រោម៖

ក_ការរួមបញ្ចូលគ្នានៃធុរកិច្ចដែលស្នើសុំនោះអាចបញ្ចប់បាន។

ខ_ការរួមបញ្ចូលគ្នានៃធុរកិច្ចដែលស្នើសុំនោះត្រូវបានចាត់ទុកជាកម្មវត្ថុនៃការត្រួតពិនិត្យបន្ទាប់។

ប្រសិនបើ **គ.ប.ក.** មិនចេញសេចក្តីជូនដំណឹងទៅភាគីជូនដំណឹង ដូចមានចែងក្នុងកថាខណ្ឌទី៣ខាងលើក្នុងរយៈពេលកំណត់នោះទេ ការរួមបញ្ចូលគ្នានៃធុរកិច្ចដែលស្នើសុំត្រូវចាត់ទុកថាអាចបញ្ចប់បាន។

ប្រសិនបើ **គ.ប.ក.** ចេញសេចក្តីជូនដំណឹងទៅភាគីជូនដំណឹង ដោយយោងតាមវាក្យខណ្ឌខនៃកថាខណ្ឌទី៣ខាងលើ សេចក្តីជូនដំណឹងនោះត្រូវបញ្ជាក់អំពីឯកសារនិងព័ត៌មានតម្រូវបន្ថែមសម្រាប់ធ្វើការត្រួតពិនិត្យបន្ទាប់ និងកាលបរិច្ឆេទកំណត់ដែលត្រូវផ្តល់មក **គ.ប.ក.**។ ក្នុងករណីភាគីជូនដំណឹង មិនអាចផ្តល់នូវឯកសារនិងព័ត៌មានបន្ថែមតាមកាលបរិច្ឆេទកំណត់ដោយ **គ.ប.ក.** ភាគីជូនដំណឹងត្រូវបញ្ជាក់នូវហេតុផលសមស្របមក **គ.ប.ក.**។ **គ.ប.ក.** មានរយៈពេល៦០(ហុកសិប)ថ្ងៃនៃថ្ងៃធ្វើការ ដើម្បីបញ្ចប់ការត្រួតពិនិត្យបន្ទាប់ ដោយគិតចាប់ពីថ្ងៃដែលភាគីជូនដំណឹងបានបំពេញគ្រប់គ្រាន់នូវឯកសារនិងព័ត៌មានតម្រូវបន្ថែមតាមសំណើរបស់ **គ.ប.ក.**។ ក្នុងរយៈពេលត្រួតពិនិត្យបន្ទាប់ **គ.ប.ក.** មានសិទ្ធិដូចខាងក្រោម៖

ក_ **គ.ប.ក.** អាចពន្យារពេលនៃការត្រួតពិនិត្យបន្ទាប់ខាងលើនេះរហូតដល់៣០(សាមសិប)ថ្ងៃនៃថ្ងៃធ្វើការចំនួន២(ពីរ)លើក តាមរយៈការចេញសេចក្តីជូនដំណឹងទៅភាគីជូនដំណឹង។

ខ_នៅក្នុងរយៈពេលនៃការត្រួតពិនិត្យបន្ទាប់ **គ.ប.ក.** អាចស្នើសុំឯកសារនិងព័ត៌មានបន្ថែមពីភាគីជូនដំណឹង តាមរយៈសេចក្តីជូនដំណឹង ដើម្បីឱ្យផ្តល់នូវឯកសារនិងព័ត៌មានបន្ថែម។ ថិរវេលាក្នុងការបញ្ចប់ការត្រួតពិនិត្យបន្ទាប់ត្រូវបានផ្អាក ដោយគិតចាប់ពីថ្ងៃដែលស្នើសុំឯកសារនិងព័ត៌មានបន្ថែមដោយ **គ.ប.ក.** រហូតដល់ភាគីជូនដំណឹងបានបំពេញតាមការស្នើសុំរបស់ **គ.ប.ក.** ឡើងវិញ។

គ_ **គ.ប.ក.** មានសិទ្ធិស្នើសុំឯកសារនិងព័ត៌មានបន្ថែមពីភាគីជូនដំណឹងនិងភាគីពាក់ព័ន្ធ តាមរយៈការអនុវត្តតួនាទីនិងភារកិច្ចរបស់ខ្លួន ស្របតាមបទប្បញ្ញត្តិនៃច្បាប់ស្តីពីការប្រកួតប្រជែង និងបទប្បញ្ញត្តិជាធរមានផ្សេងទៀត។

នៅក្នុងរយៈពេលដែលបានកំណត់ក្នុងកថាខណ្ឌទី៥ខាងលើ ដោយរួមទាំងការបន្តឬការផ្អាករយៈពេលត្រូវបានផុតកំណត់ **គ.ប.ក.** អាចចេញសេចក្តីជូនដំណឹងទៅភាគីជូនដំណឹងស្តីពីលទ្ធផលនៃការត្រួតពិនិត្យបន្ទាប់ដោយបញ្ជាក់នូវការសម្រេចណាមួយដូចខាងក្រោម៖

ក_ការរួមបញ្ចូលគ្នានៃធុរកិច្ចដែលស្នើសុំនោះអាចបញ្ចប់បាន។

ខ_ការរួមបញ្ចូលគ្នានៃធុរកិច្ចដែលស្នើសុំនោះអាចបញ្ចប់បាន ដោយត្រូវភ្ជាប់ជាមួយលក្ខខណ្ឌ។

គ_ការរួមបញ្ចូលគ្នានៃធុរកិច្ចដែលស្នើសុំនោះត្រូវបានហាមឃាត់ ដូចមានចែងក្នុងមាត្រា១១នៃច្បាប់ស្តីពីការប្រកួតប្រជែង។

ប្រសិនបើ **គ.ប.ក.** មិនបានចេញសេចក្តីជូនដំណឹងដូចមានចែងក្នុងកថាខណ្ឌទី៦ខាងលើ ក្នុងរយៈពេលដែលបានកំណត់នោះទេ ការរួមបញ្ចូលគ្នានៃធុរកិច្ចដែលស្នើសុំនោះត្រូវបានចាត់ទុកថាអាចបញ្ចប់បាន។

**មាត្រា៦ _ ការហាមឃាត់និងការបញ្ចប់នៃការរួមបញ្ចូលគ្នានៃធុរកិច្ច**

ការរួមបញ្ចូលគ្នានៃធុរកិច្ចដែលបានជូនដំណឹងជាមុន តាមកថាខណ្ឌទី១នៃមាត្រា៤នៃអនុក្រឹត្យនេះមិនអាចបញ្ចប់បានឡើយ លើកលែងតែ៖

១_ **គ.ប.ក.** ចេញសេចក្តីជូនដំណឹងទៅភាគីជូនដំណឹងថា ការរួមបញ្ចូលគ្នានៃធុរកិច្ចដែលស្នើសុំនោះអាចបញ្ចប់បាន ដូចមានចែងក្នុងវាក្យខណ្ឌកនៃកថាខណ្ឌទី៣នៃមាត្រា៥នៃអនុក្រឹត្យនេះ។

២_ **គ.ប.ក.** មិនបានចេញសេចក្តីជូនដំណឹងទៅភាគីជូនដំណឹង ក្នុងរយៈពេល៣០(សាមសិប)ថ្ងៃនៃថ្ងៃធ្វើការ បន្ទាប់ពី **គ.ប.ក.** ទទួលបានការជូនដំណឹងពេញលេញ ដូចមានចែងក្នុងកថាខណ្ឌទី៤នៃមាត្រា៥នៃអនុក្រឹត្យនេះ។

៣_ **គ.ប.ក.** ចេញសេចក្តីជូនដំណឹងទៅភាគីជូនដំណឹងថា ការរួមបញ្ចូលនៃធុរកិច្ចដែលស្នើសុំត្រូវបានចាត់ទុកជាកម្មវត្ថុនៃការត្រួតពិនិត្យបន្ទាប់ ដូចមានចែងក្នុងវាក្យខណ្ឌខនៃកថាខណ្ឌទី៣នៃមាត្រា៥នៃអនុក្រឹត្យនេះ ប៉ុន្តែក្រោយមក៖

ក_ **គ.ប.ក.** មិនបានចេញសេចក្តីជូនដំណឹងទៅភាគីជូនដំណឹង ក្នុងរយៈពេលដែលបានកំណត់ ដូចមានចែងក្នុងកថាខណ្ឌទី៦នៃមាត្រា៥នៃអនុក្រឹត្យនេះ។

ខ_ **គ.ប.ក.** ចេញសេចក្តីជូនដំណឹងទៅភាគីជូនដំណឹងថា ការរួមបញ្ចូលគ្នានៃធុរកិច្ចដែលស្នើសុំអាចបញ្ចប់បាន ដូចមានចែងក្នុងវាក្យខណ្ឌកនៃកថាខណ្ឌទី៦នៃមាត្រា៥នៃអនុក្រឹត្យនេះ។

គ_ **គ.ប.ក.** ចេញសេចក្តីជូនដំណឹងទៅភាគីជូនដំណឹងថា ការរួមបញ្ចូលគ្នានៃធុរកិច្ចដែលស្នើសុំអាចបញ្ចប់បាន ដោយត្រូវភ្ជាប់ជាមួយលក្ខខណ្ឌ ដូចមានចែងក្នុងវាក្យខណ្ឌខនៃកថាខណ្ឌទី៦នៃមាត្រា៥នៃអនុក្រឹត្យនេះ ឬត្រូវបានហាមឃាត់ ដូចមានចែងក្នុងវាក្យខណ្ឌគនៃកថាខណ្ឌទី៦នៃមាត្រា៥នៃអនុក្រឹត្យនេះ និង

- **គ.ប.ក.** ធ្វើការបញ្ជាក់ទៅភាគីជូនដំណឹង ចំពោះការបំពេញលក្ខខណ្ឌចាំបាច់ពាក់ព័ន្ធគ្រប់គ្រាន់មុននឹងបញ្ចប់ការរួមបញ្ចូលគ្នានៃធុរកិច្ចដែលស្នើសុំ
- **គ.ប.ក.** ឬតុលាការមានសមត្ថកិច្ច តាមរយៈបណ្ដឹងតវ៉ា ដូចមានចែងក្នុងមាត្រា៣១នៃច្បាប់ស្ដីពីការប្រកួតប្រជែង សម្រេចថា ការរួមបញ្ចូលគ្នានៃធុរកិច្ចដែលស្នើសុំអាចបញ្ចប់បាន។

៤_ **គ.ប.ក.** ចេញសេចក្ដីជូនដំណឹងទៅភាគីជូនដំណឹង ដូចមានចែងក្នុងវាក្យខណ្ឌកនៃកថាខណ្ឌទី៣នៃមាត្រា១០នៃអនុក្រឹត្យនេះ។

៥_ លក្ខខណ្ឌដូចមានចែងក្នុងកថាខណ្ឌទី៧នៃមាត្រា១០នៃអនុក្រឹត្យនេះ អាចអនុវត្តបាន។

៦_ **គ.ប.ក.** ចេញវិញ្ញាបនបត្រជាមុន ដូចមានចែងក្នុងកថាខណ្ឌទី១នៃមាត្រា១៤នៃអនុក្រឹត្យនេះ។

**មាត្រា៧ ._ មាតិកានៃការជូនដំណឹង**

លើកលែងតែមានការកំណត់ផ្សេងពីនេះដោយ **គ.ប.ក.** ភាគីជូនដំណឹងអំពីការរួមបញ្ចូលគ្នានៃធុរកិច្ចដូចមានចែងក្នុងកថាខណ្ឌទី១នៃមាត្រា៤នៃអនុក្រឹត្យនេះ ត្រូវផ្ដល់ឯកសារនិងព័ត៌មានពាក់ព័ន្ធដូចខាងក្រោម៖

ក_ ទម្រង់ពាក្យជូនដំណឹងដែលត្រូវកំណត់ដោយ **គ.ប.ក.**។

ខ_ ការពិពណ៌នាអំពីលក្ខខណ្ឌសំខាន់ៗនៃការព្រមព្រៀងដែលពាក់ព័ន្ធនឹងការរួមបញ្ចូលគ្នានៃធុរកិច្ចដែលស្នើសុំ រួមជាមួយសេចក្ដីព្រាងចុងក្រោយ ឬច្បាប់ចម្លងនៃកិច្ចព្រមព្រៀង ឬអនុស្សរណៈនៃការយោគយល់គ្នាដែលពាក់ព័ន្ធនឹងការរួមបញ្ចូលគ្នានៃធុរកិច្ចដែលស្នើសុំនោះ។

គ_ ឯកសារនិងព័ត៌មានរបស់ភាគីជូនដំណឹងរួមមាន៖

- ឈ្មោះបុគ្គលសម្រាប់ទាក់ទង សារអេឡិចត្រូនិក និងលេខទូរសព្ទ
- យុត្តាធិការដែលភាគីស្នើសុំស្ថិតនៅក្រោមនិងលេខចុះបញ្ជីស្របច្បាប់
- ឯកសារបញ្ជាក់សំខាន់ៗរបស់ភាគីជូនដំណឹង
- អាសយដ្ឋានដែលបានចុះបញ្ជី
- បញ្ជីរាយនាមម្ចាស់ភាគហ៊ុននៃភាគីជូនដំណឹង រួមទាំងក្រុមហ៊ុនដើមចុងក្រោយ ប្រសិនបើមាន
- បញ្ជីរាយនាមបុត្រសម្ព័ន្ធឬសមាជិកនៃក្រុមតែមួយដែលអាចមានសក្ដានុពលពាក់ព័ន្ធនឹងការត្រួតពិនិត្យលើការរួមបញ្ចូលគ្នានៃធុរកិច្ចនេះ។

ឃ_ របាយការណ៍ហិរញ្ញវត្ថុនៃភាគីជូនដំណឹងសម្រាប់ឆ្នាំមុននិងឆ្នាំធ្វើការជូនដំណឹង រួមទាំងគណនីប្រចាំត្រីមាសចុងក្រោយនៃភាគីជូនដំណឹងនោះ។

ង_ ការកំណត់អំពីប្រភេទនៃទំនិញឬសេវាដែលភាគីជូនដំណឹង(រួមបញ្ចូលទាំងបុគ្គលដែលនៅក្នុងក្រុមតែមួយជាមួយភាគីជូនដំណឹង) ពាក់ព័ន្ធដោយផ្ទាល់ឬប្រយោលនៅក្នុងការរួមបញ្ចូលគ្នានៃធុរកិច្ចកំពុងធ្វើធុរកិច្ចនៅក្នុង ឬការកំណត់អំពីចំណូលនៃភាគីជូនដំណឹងសម្រាប់២(ពីរ)ឆ្នាំមុន និងឆ្នាំដែលត្រូវធ្វើការជូនដំណឹងនៅក្នុងទីផ្សារពាក់ព័ន្ធ។

ឯកសារនិងព័ត៌មានដូចមានចែងក្នុងកថាខណ្ឌទី១ខាងលើ ត្រូវផ្ដល់ជាភាសាខ្មែរ លើកលែងតែ៖

ក_ ឈ្មោះនិងទីតាំងស្របច្បាប់របស់ភាគីជូនដំណឹង។

ខ_ ឯកសារនិងព័ត៌មានដែលត្រូវបញ្ជាក់ជាតួលេខ។

គ_ ឯកសារគតិយុត្តឬសេចក្ដីព្រាងចុងក្រោយ ប៉ុន្តែការពិពណ៌នាលក្ខខណ្ឌសំខាន់ៗនៃឯកសារទាំងនោះត្រូវផ្ដល់ជាភាសាខ្មែរ។

ឃ_ ឯកសារបញ្ជាក់សំខាន់ៗពាក់ព័ន្ធដែលត្រូវផ្ដល់ជាភាសាខ្មែរឬអង់គ្លេស។

ង_ របាយការណ៍ហិរញ្ញវត្ថុដែលត្រូវផ្ដល់ជាភាសាខ្មែរឬអង់គ្លេស។

**មាត្រា៨ ._ លក្ខណៈវិនិច្ឆ័យសម្រាប់ការត្រួតពិនិត្យបន្ទាប់**

ការរួមបញ្ចូលនៃធុរកិច្ចខ្សែដេកណាមួយមិនត្រូវចាត់ថា ស្ថិតនៅក្រោមកម្មវត្ថុនៃការត្រួតពិនិត្យបន្ទាប់ ប្រសិនបើលក្ខខណ្ឌណាមួយត្រូវបានបំពេញដូចខាងក្រោម៖

ក_ចំណែកទីផ្សារសរុបរបស់ភាគីជូនដំណឹងទាំងអស់(និងក្រុមពាក់ព័ន្ធ បើមាន) តិចជាង៣០ (សាមសិប)ភាគរយនៃទីផ្សារពាក់ព័ន្ធ។

ខ_ចំណែកទីផ្សារសរុបរបស់ភាគីជូនដំណឹងទាំងអស់(និងក្រុមពាក់ព័ន្ធ បើមាន) ស្មើឬច្រើនជាង៣០ (សាមសិប)ភាគរយនៃទីផ្សារពាក់ព័ន្ធ និងសន្ទស្សន៍អេច-អេច-អាយ នៅក្នុងទីផ្សារពាក់ព័ន្ធនោះ តិចជាង១ ៨០០(មួយពាន់ប្រាំបីរយ)។

គ_ចំណែកទីផ្សារសរុបរបស់ភាគីជូនដំណឹងទាំងអស់(និងក្រុមពាក់ព័ន្ធ បើមាន) ស្មើឬច្រើនជាង៣០ (សាមសិប)ភាគរយនៃទីផ្សារពាក់ព័ន្ធ និងសន្ទស្សន៍អេច-អេច-អាយ នៅក្នុងទីផ្សារពាក់ព័ន្ធនោះ ច្រើនជាង១ ៨០០(មួយពាន់ប្រាំបីរយ) និងកំណើនសន្ទស្សន៍អេច-អេច-អាយ នៅក្នុងទីផ្សារពាក់ព័ន្ធនោះ ក្រោយពីបញ្ចប់ការរួមបញ្ចូលគ្នានៃធុរកិច្ចដែលស្នើសុំនោះ តិចជាង១៥០(មួយរយហាសិប)។

ការរួមបញ្ចូលគ្នានៃធុរកិច្ចខ្សែឈរឬពហុផលិតផលណាមួយមិនត្រូវចាត់ទុកថា ស្ថិតក្រោមកម្មវត្ថុនៃការត្រួតពិនិត្យបន្ទាប់ ប្រសិនបើចំណែកទីផ្សាររបស់ភាគីជូនដំណឹងណាមួយ(និងក្រុមពាក់ព័ន្ធ បើមាន) តិចជាង៣០ (សាមសិប)ភាគរយនៃទីផ្សារពាក់ព័ន្ធនីមួយៗ។

ទោះបីការរួមបញ្ចូលគ្នានៃធុរកិច្ចដែលស្នើសុំនោះបានបំពេញលក្ខខណ្ឌតម្រូវ ដូចមានចែងក្នុងកថាខណ្ឌទី១ និងកថាខណ្ឌទី២ខាងលើក៏ដោយ **គ.ប.ក.** អាចធ្វើសេចក្តីសម្រេចក្នុងការកំណត់ឱ្យការរួមបញ្ចូលគ្នានៃធុរកិច្ចដែលស្នើសុំណាមួយ ឱ្យស្ថិតនៅក្រោមការត្រួតពិនិត្យបន្ទាប់បាន ប្រសិនបើ **គ.ប.ក.** មានហេតុផលសមស្របដែលអាចបញ្ជាក់ថា ការរួមបញ្ចូលគ្នានៃធុរកិច្ចដែលស្នើសុំនោះមានឬអាចមានកម្មវត្ថុ ឬអានុភាពរារាំង រឹតត្បិត ឬបង្ខូចដល់ការប្រកួតប្រជែងគួរឱ្យកត់សម្គាល់ក្នុងទីផ្សារពាក់ព័ន្ធ។ ក្នុងករណីនេះ **គ.ប.ក.** ត្រូវចេញសេចក្តីជូនដំណឹងទៅភាគីជូនដំណឹងថា ការរួមបញ្ចូលគ្នានៃធុរកិច្ចដែលស្នើសុំត្រូវបានចាត់ទុកជាកម្មវត្ថុនៃការត្រួតពិនិត្យបន្ទាប់ ដូចមានចែងក្នុងវាក្យខណ្ឌខនៃកថាខណ្ឌទី៣នៃមាត្រា៥នៃអនុក្រឹត្យនេះ ដោយបញ្ជាក់ពីហេតុផលសមស្រប។

ទោះបីការរួមបញ្ចូលគ្នានៃធុរកិច្ចដែលស្នើសុំនោះមិនបានបំពេញលក្ខខណ្ឌតម្រូវ ដូចមានចែងក្នុងកថាខណ្ឌទី១ និងកថាខណ្ឌទី២ខាងលើក៏ដោយ ក៏ **គ.ប.ក.** អាចចេញសេចក្តីសម្រេចអនុញ្ញាតឱ្យបញ្ចប់ការរួមបញ្ចូលគ្នានៃធុរកិច្ចដែលស្នើសុំណាមួយបាននិងមិនស្ថិតនៅក្រោមការត្រួតពិនិត្យបន្ទាប់ ប្រសិនបើ **គ.ប.ក.** មានហេតុផលសមស្របដែលអាចបញ្ជាក់ថា ការរួមបញ្ចូលគ្នានៃធុរកិច្ចដែលស្នើសុំនោះមិនមានឬមិនអាចមានកម្មវត្ថុ ឬអានុភាពរារាំង រឹតត្បិត ឬបង្ខូចដល់ការប្រកួតប្រជែងគួរឱ្យកត់សម្គាល់ក្នុងទីផ្សារពាក់ព័ន្ធ។ ក្នុងករណីនេះ **គ.ប.ក.** ត្រូវចេញសេចក្តីជូនដំណឹងទៅភាគីជូនដំណឹងថា ការរួមបញ្ចូលគ្នានៃធុរកិច្ចដែលស្នើសុំអាចបញ្ចប់បាន ដូចមានចែងក្នុងវាក្យខណ្ឌកនៃកថាខណ្ឌទី៣នៃមាត្រា៥នៃអនុក្រឹត្យនេះ ដោយបញ្ជាក់ពីហេតុផលសមស្រប។

**មាត្រា៩ ._ លក្ខខណ្ឌពិសេសនៃការត្រួតពិនិត្យបន្ទាប់**

ការរួមបញ្ចូលគ្នានៃធុរកិច្ចណាមួយមិនត្រូវចាត់ថា ស្ថិតនៅក្រោមកម្មវត្ថុនៃការត្រួតពិនិត្យបន្ទាប់នោះទេ ក្នុងករណីដូចខាងក្រោម៖

ក_ភាគីលក់ក្ស័យធនឬអាចក្ស័យធន។

ខ_ការទិញយកភាគហ៊ុនដែលមានសិទ្ធិបោះឆ្នោត ឬការទិញយកភាគលាភនៃការបណ្តាក់ភាគហ៊ុនរួមគ្នា ដែលធ្វើឡើងសម្រាប់តែក្នុងគោលបំណងធានាភាគហ៊ុនឬភាគលាភនោះតែប៉ុណ្ណោះ។

គ_ការទិញយកភាគហ៊ុនដែលមានសិទ្ធិបោះឆ្នោត ការទិញយកភាគលាភនៃការរួមបញ្ចូលគ្នា ឬទ្រព្យដែលអាចកើតឡើង តាមរយៈសន្តតិកម្មតាមច្បាប់ឬសន្តតិកម្មតាមមតកសាសន៍។

ឃ_ការទិញយកទ្រព្យជានាឬគណនីដែលអាចទទួលបាន ឬការទិញយកដែលកើតចេញពីការបិទ ឬការមិនសងបំណុល ឬការស្វែងរកវិធីសងបំណុលដែលធ្វើឡើងដោយម្ចាស់បំណុលស្របតាមប្រតិបត្តិការបំណុលដែលឯកភាពគ្នាដោយសុចរិតក្នុងការធ្វើធុរកិច្ចជាធម្មតា។

ភាគីជូនដំណឹងអំពីការរួមបញ្ចូលគ្នានៃធុរកិច្ច ដែលបានបំពេញលក្ខខណ្ឌដូចមានចែងក្នុងកថាខណ្ឌទី១ខាងលើ ត្រូវផ្តល់ឯកសារនិងព័ត៌មានពាក់ព័ន្ធមក **គ.ប.ក.** ដើម្បីបង្ហាញភស្តុតាងដែលបញ្ជាក់ថា លក្ខខណ្ឌទាំងនេះត្រូវបានបំពេញ។

ទោះបីលក្ខខណ្ឌដូចមានចែងក្នុងកថាខណ្ឌទី១ខាងលើ ត្រូវបានបំពេញក៏ដោយ **គ.ប.ក.** នៅតែមានសិទ្ធិធ្វើការត្រួតពិនិត្យបន្ទាប់។ ក្នុងករណីនេះ **គ.ប.ក.** ត្រូវចេញសេចក្តីជូនដំណឹងទៅភាគីជូនដំណឹងអំពីការរួមបញ្ចូលគ្នានៃធុរកិច្ចដែលស្នើសុំ ដោយបញ្ជាក់ពីហេតុផលសមស្របដែល **គ.ប.ក.** សម្រេចធ្វើការត្រួតពិនិត្យបន្ទាប់។

## មាត្រា១០ _ ការសម្រួលការជូនដំណឹងនិងការត្រួតពិនិត្យឡើងវិញ

ក្នុងករណីការរួមបញ្ចូលគ្នានៃធុរកិច្ចដែលស្នើសុំ បានបំពេញកាតព្វកិច្ចដូចមានចែងក្នុងកថាខណ្ឌទី២ខាងក្រោម និងស្ថិតក្រោមកម្មវត្ថុនៃការជូនដំណឹងជាមុនដូចមានចែងក្នុងកថាខណ្ឌទី១នៃមាត្រា៤នៃអនុក្រឹត្យនេះ ដំណើរការនៃការត្រួតពិនិត្យដូចមានចែងក្នុងមាត្រា៥នៃអនុក្រឹត្យនេះ និងមាតិកានៃការជូនដំណឹងដូចមានចែងក្នុងមាត្រា៧នៃអនុក្រឹត្យនេះ មិនត្រូវយកមកអនុវត្តឡើយ។ ការជូនដំណឹងអំពីការរួមបញ្ចូលគ្នានៃធុរកិច្ចនេះ ត្រូវភ្ជាប់មក **គ.ប.ក.** នូវឯកសារនិងព័ត៌មានពាក់ព័ន្ធ រួមមានដូចខាងក្រោម៖

ក_ទម្រង់ពាក្យជូនដំណឹងសង្ខេប ដែលត្រូវកំណត់ដោយ **គ.ប.ក.**។

ខ_ឯកសារនិងព័ត៌មានរបស់ភាគីជូនដំណឹង រួមមាន៖

- ឈ្មោះបុគ្គលសម្រាប់ទាក់ទង សារអេឡិចត្រូនិក និងលេខទូរសព្ទ
- យុត្តាធិការដែលភាគីស្នើសុំស្ថិតនៅក្រោមនិងលេខចុះបញ្ជីស្របច្បាប់
- អាសយដ្ឋានដែលបានចុះបញ្ជី
- របាយការណ៍ហិរញ្ញវត្ថុនៃភាគីជូនដំណឹងសម្រាប់ឆ្នាំមុននិងឆ្នាំដែលត្រូវធ្វើការជូនដំណឹង រួមទាំងគណនីប្រចាំត្រីមាសចុងក្រោយ។

គ_ឯកសារនិងព័ត៌មានដែលបញ្ជាក់ថា ការរួមបញ្ចូលគ្នានៃធុរកិច្ចបានបំពេញកាតព្វកិច្ច ដូចមានចែងក្នុងកថាខណ្ឌទី២ខាងក្រោម។

កាតព្វកិច្ចក្នុងការជូនដំណឹង ដូចមានចែងក្នុងកថាខណ្ឌទី១ខាងលើ ត្រូវអនុវត្តក្នុងករណី៖

ក_ភាគីជូនដំណឹងទាំងអស់នៃការរួមបញ្ចូលគ្នានៃធុរកិច្ចដែលស្នើសុំស្ថិតក្នុងក្រុមតែមួយ។

ខ_ការរួមបញ្ចូលគ្នានៃធុរកិច្ចដែលស្នើសុំ ត្រូវបានការឯកភាពពីរាជរដ្ឋាភិបាល ហើយត្រូវធ្វើការជូនដំណឹងមក **គ.ប.ក.** ក្នុងរយៈពេល៣០(សាមសិប)ថ្ងៃនៃថ្ងៃធ្វើការ បន្ទាប់ពីទទួលបានការឯកភាពនោះ។

គ_ប្រភេទនៃប្រតិបត្តិការផ្សេងទៀតដែលចេញដោយ **គ.ប.ក.**។

បន្ទាប់ពីទទួលបានការជូនដំណឹង ដូចមានចែងក្នុងកថាខណ្ឌទី១ខាងលើ **គ.ប.ក.** ត្រូវចេញសេចក្តីជូនដំណឹងទៅភាគីជូនដំណឹង ក្នុងរយៈពេល៧(ប្រាំពីរ)ថ្ងៃនៃថ្ងៃធ្វើការ ដោយបញ្ជាក់ថា៖

ក_ការរួមបញ្ចូលគ្នានៃធុរកិច្ចដែលស្នើសុំ បានបំពេញកាតព្វកិច្ចដូចមានចែងក្នុងកថាខណ្ឌទី២ខាងលើ ហើយការជូនដំណឹងនោះពិតជាត្រឹមត្រូវនិងគ្រប់គ្រាន់។

ខ_ឯកសារនិងព័ត៌មានដែលបានប្រគល់មក ពាក់ព័ន្ធនឹងការជូនដំណឹងនៃការរួមបញ្ចូលគ្នានៃធុរកិច្ចដែលស្នើសុំ មានលក្ខណៈមិនគ្រប់គ្រាន់ក្នុងការកំណត់ថា ការរួមបញ្ចូលគ្នានៃធុរកិច្ចដែលស្នើសុំនោះបានបំពេញកាតព្វកិច្ចដូចមានចែងក្នុងកថាខណ្ឌទី២ខាងលើ។

គ_ការរួមបញ្ចូលគ្នានៃធុរកិច្ចដែលស្នើសុំ មិនបានបំពេញកាតព្វកិច្ចដូចមានចែងក្នុងកថាខណ្ឌទី២ ខាងលើ។

ក្នុងករណី **គ.ប.ក.** ចេញសេចក្តីជូនដំណឹងអំពីភាពមិនគ្រប់គ្រាន់នៃឯកសារនិងព័ត៌មាន ភាគីជូនដំណឹងមានរយៈពេល៧(ប្រាំពីរ)ថ្ងៃនៃថ្ងៃធ្វើការ ក្នុងការផ្តល់នូវឯកសារនិងព័ត៌មានឱ្យបានគ្រប់គ្រាន់ ដើម្បីឱ្យ **គ.ប.ក.** អាចចេញសេចក្តីជូនដំណឹងបញ្ជាក់ថា ការជូនដំណឹងនោះពិតជាត្រឹមត្រូវនិងគ្រប់គ្រាន់ ដូចមានចែងក្នុងវាក្យខណ្ឌកនៃកថាខណ្ឌទី៣នៃមាត្រា១០នៃអនុក្រឹត្យនេះ។ ក្នុងករណីគ្មានឯកសារនិងព័ត៌មានបន្ថែមគ្រប់គ្រាន់ត្រូវបានផ្តល់ជូនក្នុងរយៈពេលដែលបានកំណត់ **គ.ប.ក.** ត្រូវចេញសេចក្តីជូនដំណឹងទៅភាគីជូនដំណឹងដោយបញ្ជាក់ថា ការរួមបញ្ចូលគ្នានៃធុរកិច្ចដែលស្នើសុំ មិនបានបំពេញកាតព្វកិច្ចដូចមានចែងក្នុងវាក្យខណ្ឌគនៃកថាខណ្ឌទី៣នៃមាត្រា១០នៃអនុក្រឹត្យនេះ។

**គ.ប.ក.** ត្រូវចេញសេចក្តីជូនដំណឹងក្នុងរយៈពេល៧(ប្រាំពីរ)ថ្ងៃនៃថ្ងៃធ្វើការ ដូចមានចែងក្នុងវាក្យខណ្ឌក ឬវាក្យខណ្ឌគនៃកថាខណ្ឌទី៣នៃមាត្រា១០នៃអនុក្រឹត្យនេះ ដល់ភាគីជូនដំណឹង បន្ទាប់ពីទទួលបានឯកសារនិងព័ត៌មានពាក់ព័ន្ធបន្ថែម ដោយអនុវត្តនីតិវិធីដូចមានចែងក្នុងកថាខណ្ឌទី៤ខាងលើ។

ក្នុងករណី **គ.ប.ក.** ចេញសេចក្តីជូនដំណឹងទៅភាគីជូនដំណឹងថា ការរួមបញ្ចូលគ្នានៃធុរកិច្ចដែលស្នើសុំ មិនបានបំពេញកាតព្វកិច្ចដូចមានចែងក្នុងវាក្យខណ្ឌគនៃកថាខណ្ឌទី៣ខាងលើ ការជូនដំណឹងអំពីការរួមបញ្ចូលគ្នានៃធុរកិច្ចដែលស្នើសុំ ត្រូវអនុវត្តតាមនីតិវិធីដូចមានចែងក្នុងមាត្រា៥និងមាត្រា៧នៃអនុក្រឹត្យនេះ។

ក្នុងករណី **គ.ប.ក.** មិនបានចេញសេចក្តីជូនដំណឹង ដូចមានចែងក្នុងកថាខណ្ឌទី៣និងកថាខណ្ឌទី៥ខាងលើ នោះការជូនដំណឹងអំពីការរួមបញ្ចូលគ្នានៃធុរកិច្ចដែលស្នើសុំនោះ ត្រូវបានចាត់ទុកថាត្រឹមត្រូវនិងគ្រប់គ្រាន់។

**មាត្រា១១ .- ការលើកលែង**

ភាគីស្នើសុំការលើកលែង ដូចមានចែងក្នុងមាត្រា១២នៃច្បាប់ស្តីពីការប្រកួតប្រជែង ត្រូវផ្តល់នូវឯកសារនិងព័ត៌មាននៅពេលធ្វើការជូនដំណឹង ដូចមានចែងក្នុងមាត្រា៥នៃអនុក្រឹត្យនេះ ឬនៅពេលដាក់ស្នើសុំវិញ្ញាបនបត្រជាមុន ដូចមានចែងក្នុងមាត្រា១៤នៃអនុក្រឹត្យនេះ ឬនៅពេលណាមួយក្នុងរយៈពេលដំណើរការត្រួតពិនិត្យឡើងវិញ ដើម្បីបង្ហាញភស្តុតាងដល់ **គ.ប.ក.** ក្នុងការបញ្ជាក់ថា ការរួមបញ្ចូលគ្នានៃធុរកិច្ចដែលស្នើសុំបានបំពេញតាមលក្ខខណ្ឌដូចមានចែងក្នុងមាត្រា១២នៃច្បាប់ស្តីពីការប្រកួតប្រជែង។

**គ.ប.ក.** ត្រូវពិនិត្យលើអត្ថប្រយោជន៍ដ៏មានប្រសិទ្ធភាព ដែលអាចបង្ហាញឱ្យឃើញនិងរំពឹងទុកថា កើតចេញពីការរួមបញ្ចូលគ្នានៃធុរកិច្ចដែលស្នើសុំនោះ ដោយរួមបញ្ចូលទាំងប្រសិទ្ធភាពនៃវិភាជ ប្រសិទ្ធភាពផលិតកម្ម និងប្រសិទ្ធភាពថាមវន្ត នៅពេលកំណត់អត្ថប្រយោជន៍ផ្នែកបច្ចេកវិទ្យា សេដ្ឋកិច្ច ឬសង្គម ហើយអត្ថប្រយោជន៍ទាំងនោះនឹងមិនកើតមានឡើងឡើយ ប្រសិនបើគ្មានការរួមបញ្ចូលគ្នានៃធុរកិច្ចដែលបានស្នើសុំនេះ ដូចមានចែងក្នុងចំណុចទី១ និងចំណុចទី២នៃមាត្រា១២នៃច្បាប់ស្តីពីការប្រកួតប្រជែង។

**គ.ប.ក.** ត្រូវផ្តោតលើផលប្រយោជន៍ដែលអាចកំណត់បាននិងកើតចេញពីការរួមបញ្ចូលគ្នានៃធុរកិច្ចដែលស្នើសុំនិងផលប៉ះពាល់ដល់ការប្រកួតប្រជែងដែលត្រូវបានពិចារណា ដូចមានចែងក្នុងចំណុចទី៣និងចំណុចទី៤នៃមាត្រា១២នៃច្បាប់ស្តីពីការប្រកួតប្រជែង ក្នុងទីផ្សារនៃព្រះរាជាណាចក្រកម្ពុជា នៅពេលវាយតម្លៃលើការស្នើសុំការលើកលែង ដូចមានចែងក្នុងមាត្រា១២នៃច្បាប់ស្តីពីការប្រកួតប្រជែង។

**មាត្រា១២ .- កាតព្វកិច្ចក្នុងការចុះបញ្ជីក្រោយសម្រេចទាំងស្រុងនូវការរួមបញ្ចូលគ្នានៃធុរកិច្ច**

ភាគីមួយក្នុងចំណោមភាគីជូនដំណឹងអំពីការរួមបញ្ចូលគ្នានៃធុរកិច្ច ដែលត្រូវបានអនុញ្ញាតដោយ **គ.ប.ក.** ដូចមានចែងក្នុងមាត្រា៦និងមាត្រា១០នៃអនុក្រឹត្យនេះ ត្រូវរាយការណ៍អំពីស្ថានភាពនៃការរួមបញ្ចូលគ្នានៃធុរកិច្ច និងចុះបញ្ជីការរួមបញ្ចូលគ្នានៃធុរកិច្ចនោះក្នុងរយៈពេល៣០(សាមសិប)ថ្ងៃនៃថ្ងៃធ្វើការ ក្រោយពីការបញ្ចប់ផ្នែកសំខាន់ៗលើការរួមបញ្ចូលគ្នានៃធុរកិច្ច ដោយភ្ជាប់មកជាមួយនូវលិខិតបញ្ជាក់កាតព្វកិច្ចសារពើពន្ធពីអគ្គនាយកដ្ឋានពន្ធដារនៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ។

លក្ខខណ្ឌនិងនីតិវិធីនៃការចុះបញ្ជីការរួមបញ្ចូលគ្នានៃធុរកិច្ចដែលត្រូវជូនដំណឹងជាមុន ត្រូវកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម។

## ជំពូកទី៣
## ការជូនដំណឹងក្រោយពីសម្រេចការរួមបញ្ចូលគ្នានៃធុរកិច្ច

### មាត្រា១៣.- កាតព្វកិច្ចក្រោយសម្រេចការរួមបញ្ចូលគ្នានៃធុរកិច្ច

ភាគីមួយក្នុងចំណោមភាគីជូនដំណឹងអំពីការរួមបញ្ចូលគ្នានៃធុរកិច្ច ដែលមិនមានកាតព្វកិច្ចជូនដំណឹងដូចមានចែងក្នុងមាត្រា៤នៃអនុក្រឹត្យនេះ ត្រូវជូនដំណឹងការរួមបញ្ចូលគ្នានៃធុរកិច្ចនៅ **គ.ប.ក.** ក្រោយពីការបញ្ចប់ផ្នែកសំខាន់ៗនៃការរួមបញ្ចូលគ្នានៃធុរកិច្ច។

នីតិវិធីនៃការជូនដំណឹងជាក្រោយនៃការរួមបញ្ចូលគ្នានៃធុរកិច្ច ត្រូវកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម។

## ជំពូកទី៤
## ការចេញវិញ្ញាបនបត្រជាមុន

### មាត្រា១៤.- ការចេញវិញ្ញាបនបត្រជាមុន

ភាគីជូនដំណឹងអំពីការរួមបញ្ចូលគ្នានៃធុរកិច្ចអាចស្នើសុំវិញ្ញាបនបត្រជាមុនពី **គ.ប.ក.**។

ក្នុងករណី **គ.ប.ក.** មិនមានអំណះអំណាងណាមួយក្នុងការបដិសេធឬចាប់ផ្ដើមដំណើរការហាមឃាត់ការរួមបញ្ចូលគ្នានៃធុរកិច្ច ដូចមានចែងក្នុងមាត្រា១១នៃច្បាប់ស្ដីពីការប្រកួតប្រជែងនោះទេ **គ.ប.ក.** អាចចេញវិញ្ញាបនបត្រជាមុនបាន។

ក្នុងករណី **គ.ប.ក.** ចេញនូវវិញ្ញាបនបត្រជាមុនណាមួយ ដូចមានចែងក្នុងកថាខណ្ឌទី១ខាងលើ ការរួមបញ្ចូលគ្នានៃធុរកិច្ចដែលជាកម្មវត្ថុនៃការចេញវិញ្ញាបនបត្រជាមុននោះ អាចបញ្ចប់ផ្នែកសំខាន់ៗបាន។ ក្នុងរយៈពេល១(មួយ)ឆ្នាំ ដោយគិតចាប់ពីថ្ងៃចេញវិញ្ញាបនបត្រជាមុន **គ.ប.ក.** មិនអាចបដិសេធឬហាមឃាត់ការរួមបញ្ចូលគ្នានៃធុរកិច្ច ដូចមានចែងក្នុងមាត្រា១១នៃច្បាប់ស្ដីពីការប្រកួតប្រជែង ដោយផ្អែកតែលើមូលដ្ឋាននៃឯកសារនិងព័ត៌មានដូចគ្នា ដែលបានដាក់ស្នើសុំសម្រាប់ជាមូលដ្ឋាននៃការចេញនូវវិញ្ញាបនបត្រជាមុននោះឡើយ។

ការចេញវិញ្ញាបនបត្រជាមុន ដូចមានចែងក្នុងកថាខណ្ឌទី១ខាងលើ ត្រូវចាត់ទុកថាបានបំពេញកាតព្វកិច្ចជូនដំណឹងអំពីការរួមបញ្ចូលគ្នានៃធុរកិច្ច ដូចមានចែងក្នុងមាត្រា៤នៃអនុក្រឹត្យនេះ។ កាតព្វកិច្ចចុះបញ្ជីដូចមានចែងក្នុងមាត្រា១២នៃអនុក្រឹត្យនេះ ត្រូវអនុវត្ត ទោះបីវិញ្ញាបនបត្រជាមុននៃការរួមបញ្ចូលគ្នានៃធុរកិច្ចត្រូវបានចេញក៏ដោយ។

បែបបទនិងនីតិវិធីនៃការចេញវិញ្ញាបនបត្រជាមុន ត្រូវកំណត់ដោយសេចក្ដីសម្រេចរបស់ **គ.ប.ក.**។

## ជំពូកទី៥
## កម្រៃសេវានិងសេចក្ដីសម្រេច

### មាត្រា១៥.- កម្រៃសេវា

កម្រៃសេវាពាក់ព័ន្ធនឹងការជូនដំណឹង ដូចមានចែងក្នុងមាត្រា៤ មាត្រា១០ ឬមាត្រា១៣នៃអនុក្រឹត្យនេះ ការចេញវិញ្ញាបនបត្រជាមុននិងការចុះបញ្ជីការរួមបញ្ចូលគ្នានៃធុរកិច្ច ត្រូវកំណត់ដោយប្រកាសអន្តរក្រសួងរវាងរដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្មនិងរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ។

### មាត្រា១៦.- សេចក្ដីសម្រេច

សេចក្ដីសម្រេចណាមួយដែលចេញដោយ **គ.ប.ក.** លើការរួមបញ្ចូលគ្នានៃធុរកិច្ច ទោះជាមានភ្ជាប់លក្ខខណ្ឌការហាមឃាត់នៃការរួមបញ្ចូលគ្នានៃធុរកិច្ច ឬការចេញវិញ្ញាបនបត្រជាមុន ត្រូវជាសេចក្ដីសម្រេចដែលមានអានុភាពអនុវត្ត ដោយអនុលោមតាមជំពូកទី៥នៃច្បាប់ស្ដីពីការប្រកួតប្រជែង។

## ជំពូកទី៦
## ទណ្ឌកម្ម

**មាត្រា១៧ ._ ទណ្ឌកម្ម**

ភាគីរួមបញ្ចូលគ្នានៃធុរកិច្ចដែលបំពានបទប្បញ្ញត្តិនៃអនុក្រឹត្យនេះ ត្រូវទទួលទណ្ឌកម្មរដ្ឋបាល និង/ឬ ទណ្ឌកម្មផ្សេងទៀត ស្របតាមច្បាប់ស្ដីពីការប្រកួតប្រជែងនិងលិខិតបទដ្ឋានគតិយុត្តជាធរមាន។

## ជំពូកទី៧
## អវសានប្បញ្ញត្តិ

**មាត្រា១៨** ._ រយៈពេលអនុវត្ត

ក្នុងរយៈពេល៦(ប្រាំមួយ)ខែ បន្ទាប់ពីអនុក្រឹត្យនេះចូលជាធរមាន ភាគីរួមបញ្ចូលគ្នានៃធុរកិច្ចត្រូវអនុវត្ត តាមបទប្បញ្ញត្តិនៃអនុក្រឹត្យនេះ។

**មាត្រា១៩** ._ ការទុកជានិរាករណ៍

បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងអនុក្រឹត្យនេះ ត្រូវទុកជានិរាករណ៍។

**មាត្រា២០** ._ បញ្ញត្តិអនុវត្ត

រដ្ឋមន្ត្រីទទួលបន្ទុកទីស្ដីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម រដ្ឋមន្ត្រីគ្រប់ក្រសួងនិងប្រធានគ្រប់ស្ថាប័នដែលពាក់ព័ន្ធ ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះ តាមភារកិច្ចរៀងៗខ្លួន ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ថ្ងៃច័ន្ទ ១៥ កើត ខែ ផល្គុន ឆ្នាំខាល ចត្វាស័ក ព.ស.២៥៦៦

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ៦ ខែ មីនា ឆ្នាំ២០២៣

**នាយករដ្ឋមន្ត្រី**

**សម្ដេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

បានយកសេចក្ដីគោរពជម្រាបជូន

សម្ដេចអគ្គមហាសេនាបតីតេជោនាយករដ្ឋមន្ត្រីសូមហត្ថលេខា

**រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម**

**ប៉ាន សូរស័ក្តិ**

**កន្លែងទទួល** :

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្ដេចអគ្គមហាសេនាបតីតេជោនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យសម្ដេច ឯកឧត្ដម លោកជំទាវឧបនាយករដ្ឋមន្ត្រី
- ដូចមាត្រា២០
- រាជកិច្ច
- ឯកសារ កាលប្បវត្តិ